ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ
លេខ : ២៥/២០០៧ កបធ.សសរ

# វិសោធនកម្មបទបញ្ជាផ្ទៃក្នុង
# ស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០២០ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ១៩៩៨
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើវិសោធនកម្ម នាថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៩៨

- បានឃើញបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើវិសោធនកម្ម នាថ្ងៃទី ០៧ ខែ សីហា ឆ្នាំ២០០៧
- បានឃើញបទបញ្ជាស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ លេខ ២៤ កបធ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ១៩៩៨
- បានឃើញសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ០៥/៩៩ កបធ.ច.សសរ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩ ស្តីពីការកែសម្រួលលើបទបញ្ជាស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ

## សម្រេច

**ប្រការមួយ .-**

ចំណងជើងនៃជំពូកទី១ ប្រការ១ ចំណងជើងនៃជំពូកទី២ ប្រការ ៨ និង ប្រការ ១០ នៃ បទបញ្ជាផ្ទៃក្នុង ស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ លេខ ២៤ កបធ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ១៩៩៨ ត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោម ៖

ជំពូកទី១ថ្មី

នីតិវិធីទាក់ទងនឹងការបកស្រាយរដ្ឋធម្មនុញ្ញ បកស្រាយច្បាប់

ការពិនិត្យធម្មនុញ្ញភាពនៃច្បាប់ និង សេចក្តីសម្រេចនៃស្ថាប័ននានារបស់រដ្ឋ

ប្រការ ១ ថ្មី

អនុលោមតាមមាត្រា១៥ថ្មី មាត្រា១៦ថ្មី មាត្រា១៧ថ្មី មាត្រា១៨ថ្មី និង មាត្រា១៩ នៃច្បាប់ ស្តីពីការរៀបចំនិង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ក្រោយពីបានទទួលសំណើពីព្រះមហាក្សត្រ ពីប្រធានព្រឹទ្ធសភា ពីប្រធានរដ្ឋសភា ពីនាយករដ្ឋមន្ត្រី ពីសមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន ពីសមាជិករដ្ឋសភាចំនួនមួយភាគដប់ ពីតុលាការ ពីប្រជារាស្ត្រ តាមរយៈប្រធានរដ្ឋសភា ឬ សមាជិករដ្ឋសភាចំនួនមួយភាគដប់ ឬ ប្រធានព្រឹទ្ធសភា ឬ សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន ឬ ពីតុលាការកំពូល ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវចាត់ឱ្យចុះបញ្ជីនៅ អគ្គលេខាធិការដ្ឋាន ។

ជំពូកទី២ថ្មី

នីតិវិធីអំពីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា

ប្រការ ៨ ថ្មី

អនុលោមតាមមាត្រា២៥ ថ្មី មាត្រា២៦ និង មាត្រា២៧ ថ្មី នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃ ក្រុមប្រឹក្សាធម្មនុញ្ញ វិវាទកម្មដែលទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ការបោះឆ្នោតជ្រើសតាំង សមាជិកព្រឹទ្ធសភា ត្រូវសម្រេចដោយក្រុមប្រឹក្សាធម្មនុញ្ញ ។

ប្រការ ១០ ថ្មី

ដើម្បីស្រាវជ្រាវស៊ើបអង្កេតអំពីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ការបោះឆ្នោត ជ្រើសតាំងសមាជិកព្រឹទ្ធសភា ក្រុមប្រឹក្សាធម្មនុញ្ញត្រូវអនុវត្តតាមមាត្រា ៣០ថ្មី មាត្រា៣១ មាត្រា៣២ មាត្រា៣៣ និង មាត្រា ៣៤ ថ្មីនៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ និង តាមប្រការ ៣ ប្រការ ៤ ប្រការ ៥ និង

ប្រការ ៦ នៃបទបញ្ជាផ្ទៃក្នុងនេះ ។

**ប្រការពីរ.-**

វិសោធនកម្មបទបញ្ជាផ្ទៃក្នុងស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញនេះ ត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញអនុម័តកាលពីថ្ងៃទី ០៩ ខែ សីហា ឆ្នាំ២០០៧ នាពេលប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ហើយត្រូវបានដាក់ឱ្យអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០៧

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

**<u>កន្លែងទទួល</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាននៃព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាននៃរដ្ឋសភា
- ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី " ដើម្បីចុះផ្សាយក្នុងរាជកិច្ច "
- កាលប្បវត្តិ - ឯកសារ